# ចតុប្បារិសុទ្ធិសីល

គណៈកម្មការធម្មវិន័យ

រៀបរៀង

ក្រោមព្រះបរមរាជូបត្ថម្ភ

សំរាប់សាលាធម្មវិន័យ

ព.ស ២៥៤៣ គ.ស ១៩៩៩

អំណោយពីលោក ខ្លៅ ឃុនសំរិន សល់កុណាខ្មែរ ដើម្បីតំកល់ទុកក្នុង elibrary of Cambodia កញ្ញា 2015

# ចតុប្បារិសុទ្ធិសីល

គណៈកម្មការធម្មវិន័យ

រៀបរៀង

ក្រោមព្រះបរមរាជូបត្ថម្ភ

សំរាប់សាលាធម្មវិន័យ

ព.ស ២៥៤៣ គ.ស ១៩៩៩

# បាតិមោក្ខសំវរសីល

## អនុសាសនៈ៨យ៉ាង

ពាក្យប្រៀនប្រដៅចំពោះភិក្ខុ ដែលបានឧបសម្បទាថ្មីៗ ក្នុងពេលជាលំដាប់ បន្ទាប់អំពីកម្មវាចាមក ដើម្បីឱ្យចេះដឹងបណ្ដើរ ជាការបណ្ដោះអាសន្ន ហៅថា អនុសាសនៈ មាន៨យ៉ាង គឺ និស្ស័យ ៤, អករណីយកិច្ច ៤ ។

បច្ច័យជាគ្រឿងអាស្រ័យរបស់បព្វជិត ហៅថា និស្ស័យ មាន៤យ៉ាង គឺ ដើរបិណ្ឌបាត១, ស្លៀកដណ្ដប់សំពត់បំសុកូល១, នៅអាស្រ័យក្រោមម្លប់ឈើ១, ឆាន់ថ្នាំដែលត្រាំដោយទឹកមូត្រ១ ។

កិច្ចដែលបព្វជិតមិនមិនត្រូវធ្វើ ហៅថា អករណីយកិច្ច មាន៤យ៉ាង គឺ សេពមេថុនធម្ម១, លួចទ្រព្យគេ១, សំលាប់សត្វ១, ពោលអួតគុណវិសេស ដែលមិនមានក្នុងខ្លួន១ ។

## ត្រៃសិក្ខា

គុណ-ជាតិ ដែលបព្វជិតត្រូវសិក្សា ហៅថា សិក្ខា មាន៣យ៉ាង គឺ សីល១, សមាធិ១, បញ្ញា១ ។

១-ការសង្រួមកាយ វាចាដោយប្រពៃហៅថា សីល ។

២-ការរក្សាចិត្តអោយស្ងប់រំងាប់ហៅថា សមាធិ ។

៣-ការដឹងច្បាស់ក្នុងកងសង្ខារហៅថា បញ្ញា ។

# អាបត្តិ

ទោសដែលកើតឡើង ព្រោះសេចក្ដីល្មើសវិនយបញ្ញត្តិ ដែលព្រះសមាសម្ពុទ្ធទ្រង់ហាម ហៅថា អាបត្តិៗ នោះពោលដោយឈ្មោះមាន៧យ៉ាង គឺ : បារាជិក១, សង្ឃាទិសេស១, ថុល្លច្ច័យ១, បាចិត្តិយ១, បាដិទេសនិយ១, ទុក្កដ១, ទុព្ភាសិត១ ។

បារាជិក បើភិក្ខុត្រូវហើយ ក៏ដាច់ចាកភិក្ខុភាវ: ។ សង្ឃាទិសេស បើភិក្ខុត្រូវហើយ ត្រូវចូលបរិវាសកម្ម ទើបរួចចាកអាបត្តិបាន ។ អាបត្តិទាំង៥យ៉ាង ក្រៅពីនោះ បើភិក្ខុត្រូវហើយ ត្រូវសំដែងចំពោះមុខសង្ឃ ឬគណ: ឬក៏បុគ្គល ទើបរួចចាកទោសបាន ។

# អាបត្តាបត្តិនាការ

អាការដែលភិក្ខុ នឹងត្រូវអាបត្តិទាំងនោះមាន ៦ យ៉ាង គឺ

១-អលជ្ជិតា ត្រូវដោយមិនមានខ្មាស ។

២-អញ្ញាណតា ត្រូវដោយមិនស្គាល់អាបត្តិ ។

៣-កុក្កុច្ចប្បកតត្តា ត្រូវដោយសង្ស័យហើយចេះតែធ្វើ ។

៤-អកប្បិយេ កប្បិយសញ្ញិតា ត្រូវដោយសំគាល់ថាគួរ ក្នុងរបស់ដែលមិនគួរ ។

៥-កប្បិយេ អកប្បិយសញ្ញិតា ត្រូវដោយសំគាល់ថាមិនគួរក្នុងរបស់គួរដែលគួរ ។

៦-សតិសម្មោសា ត្រូវដោយភ្លេចស្មារតី ។

## សិក្ខាបទ

វិនយបញ្ញត្តិ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាម លើកឡើងជាប្រការ ឬ ជាមាត្រាមួយៗ ដែលហៅថា សិក្ខាបទ នោះមានក្នុងបាតិមោក្ខៈ មិនមានក្នុងបាតិមោក្ខៈ ។ សិក្ខាបទដែលមានក្នុងបាតិមោក្ខនោះគឺ ៈបារាជិក ៤, សង្ឃាទិសេស ១៣, អនិយត ២, និស្សគ្គិយបាចិត្តិយ ៣០, សុទ្ធិកបាចិត្តិយ ៩២, បាដិទេសនីយ ៤, សេក្ខិយវត្ត ៧៥ រួមជា ២២០ រាប់ទាំង អធិករណសមថ ៧ ផង ផងជា ២២៧ ។

## បារាជិក ៤

១-មេថុនធម្ម ភិក្ខុសេពមេថុនធម្ម ត្រូវបារាជិក ។

២-អទិន្នាទាន ភិក្ខុលួចទ្រព្យគេ ដោយយ៉ាងតិចបំផុត តាំងពីត្រឹម

តំលៃ ៥មាស ឡើងទៅ ត្រូវបារាជិក ។

៣-មនុស្សវិគ្គហ ភិក្ខុក្លែងសំលាប់មនុស្ស ត្រូវបារាជិក ។

៤-ឧត្តរិមនុស្សធម្ម ភិក្ខុពោលអួតឧត្តរិមនុស្សធម្ម គឺធម៌របស់មនុស្ស ក្រៃលែង ដែលមិនមានក្នុងខ្លួន ត្រូវបារាជិក ។

## សង្ឃាទិសេស ១៣

១-សុក្កវិសដ្ឋិ ភិក្ខុក្លែងញ៉ាំងទឹកសុក្កៈឱ្យកំរើកឃ្លាតចាកទី ត្រូវសង្ឃាទិសេស ។

២-កាយសំសគ្គ ភិក្ខុមានតំរេក ត្រូវសង្ឃាទិសេស ។

៣-ទុដ្ឋុល្លវាចា ភិក្ខុមានតំរេក និយាយពាក្យអាក្រក់ចំពោះនិមិត្តស្រ្តី ត្រូវសង្ឃាទិសេស ។

៤-អត្តកាមបារិចរិយា ភិក្ខុមានតំរេក និយាយល្បួងស្រ្តីឱ្យបំរើខ្លួនដោយកាម ត្រូវសង្ឃាទិសេស ។

៥-សញ្ចរិត្ត ភិក្ខុនិយាយដឹកនាំឱ្យបុរសស្រ្តីបានគ្នាជាប្តីប្រពន្ធ ត្រូវសង្ឃាទិសេស ។

៦-សញ្ញាចិកា ភិក្ខុធ្វើកុដិបួកដោយកំបោរ ឬដីស្អិត មិនមានអ្នកណាជាម្ចាស់ របស់ចំពោះជាទីលំនៅរបស់ខ្លួន ត្រូវធ្វើឱ្យត្រូវនឹងប្រមាណ

គឺបណ្ដោយ ១២ចំអាម ទទឹង ៧ចំអាម ដោយចំអាមព្រះសុគត កាលដែលនឹងធ្វើនោះ ត្រូវឱ្យសង្ឃសំដែងទីឱ្យជាមុន បើមិនបានឱ្យសង្ឃសំដែងទីឱ្យក្ដី ធ្វើឱ្យកន្លង ហួសប្រមាណក្ដី ត្រូវសង្ឃាទិសេស ។ (សិក្ខាបទនេះហៅថា កុដិការ ក៏បាន ) ។

៧-មហល្លក បើកុដិដែលធ្វើនោះ មានទាយកជាម្ចាស់របស់ ធ្វើឱ្យកន្លងហួសប្រមាណនោះបាន ប៉ុន្តែត្រូវឱ្យសង្ឃសំដែងទីឱ្យជាមុន បើមិនឱ្យសង្ឃសំដែងឱ្យ ត្រូវសង្ឃាទិសេស ។

៨-អមូលក ភិក្ខុក្រោធខឹងនឹងភិក្ខុឯទៀត ហើយក្លែងចោទគេដោយអាបត្តិបារាជិកមិនមានមូល ត្រូវសង្ឃាទិសេស ។

៩-អញ្ញភាគិយ ភិក្ខុក្រោធខឹងនឹងភិក្ខុឯទៀត ហើយក្លែងលេសមកចោទគេ ដោយអាបត្តិបារាជិក ត្រូវសង្ឃាទិសេស ។

១០-សង្ឃភេទ ភិក្ខុព្យាយាមបំបែកសង្ឃឱ្យបែកគ្នា ភិក្ខុដទៃហាមប្រាមមិនស្ដាប់. សង្ឃបានសូត្យ សមនុភាសនកម្ម ដើម្បីឱ្យលះបង់. បើមិនលះបង់ ត្រូវសង្ឃាទិសេស ។

១១-ភេទានុវត្តក ភិក្ខុប្រព្រឹត្តិតាមភិក្ខុដែលបំបែកសង្ឃនោះ ភិក្ខុដទៃហាមប្រាមមិនស្ដាប់. សង្ឃបានសូត្យ សមនុភាសនកម្ម ដើម្បីឱ្យលះបង់ បើមិនលះ បង់ ត្រូវសង្ឃាទិសេស ។

១២-ឧក្ខេបនិយកម្ម ភិក្ខុមានជាតិជាអ្នកប្រដៅក្រ. ភិក្ខុដទៃឯទៀតហាមមិនស្តាប់. សង្ឃបានសូត្រ សមនុភាសនកម្ម ដើម្បីឱ្យលះបង់ បើមិនលះបង់ ត្រូវសង្ឃាទិសេស ។

១៣-កុលទូសក ភិក្ខុទ្រុស្តត្រកូល គឺភិក្ខុដែលប្រចុបប្រចែងគ្រហស្ថ. សង្ឃបានបណ្តេញចេញអំពីវត្តហើយ. ត្រឡប់តិះដៀលសង្ឃវិញ. សង្ឃបានសូត្រ សមនុភាសនកម្ម ដើម្បីឱ្យលះបង់ បើមិនលះបង់ ត្រូវសង្ឃាទិសេស ។

តាំងពី សុក្កវិស្សដ្ឋិ ដល់ អញ្ញភាគិយ ៩ សិក្ខាបទនេះ ឈ្មោះ បឋមាបត្តិកា ព្រោះត្រូវក្នុងខណៈដែលកន្លងជាដំបូង. ក្រៅពីនោះ ៤ សិក្ខាបទ ទៀតឈ្មោះ យាវតតិយកា ព្រោះត្រូវក្នុងខណៈ ដែលសង្ឃសូត្រ សមនុភាសនកម្ម ចប់អនុស្សាវនាជាគំរប់ ៣ ។

## អនិយត ២

១-អបេកម្មនិយ ភិក្ខុអង្គុយក្នុងទីកំបាំងភ្នែកតែពីរនាក់នឹងស្ត្រី បើមាន មនុស្ស ដែលគួរជឿបាន ពោលពាក្យចោទដោយអាបត្តិ ៣ យ៉ាង គឺ បារាជិក ឬ សង្ឃាទិសេស ឬ បាចិត្តិយ អាបត្តិណាមួយ. បើ ភិក្ខុទទួលប្តេជ្ញាដោយអាបត្តិណា ឬ គេចោទចំពោះអាបត្តិណា ឱ្យវិន័យ ធរកាត់ទោសចំពោះអាបត្តិ នោះ ។

២-នាលំកម្មនិយភិក្ខុអង្គុយក្នុងទីកំបាំងត្រចៀកតែពីរនាក់នឹងស្ត្រី បើមានមនុស្ស ដែលគួរជឿបាន ពោលចោទដោយអាបត្តិ ២ យ៉ាង គឺ សង្ឃាទិសេស ឬ បាចិត្តិយ អាបត្តិណាមួយ. បើភិក្ខុទទួលប្តេជ្ញា ដោយអាបត្តិណា ឬ គេចោទចំពោះអាបត្តិណា ឱ្យវិន័យធរកាត់ទោស ចំពោះអាបត្តិនោះ ។

## និស្សគ្គិយបាចិត្តិយ ៣០

និស្សគ្គិយបាចិត្តិយ ៣០ ចែកចេញជាវគ្គមាន៣គឺ ចីវរវគ្គ១, កោសិយវគ្គ១, បត្តវគ្គ១, ក្នុងវគ្គមួយៗ មានសិក្ខាបទដប់ៗ ។

## ចីវរវគ្គទី ១

១-បឋមកឋិន កាលបើអស់អំណាចអានិសង្សកឋិន ហើយភិក្ខុទុកអតិរេកចីវរបានយ៉ាងយូរបំផុតត្រឹម ១០ថ្ងៃ. បើទុកឱ្យកន្លងហួសពីនោះទៅ ត្រូវនិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

២-ទុតិយកឋិន កាលបើអស់អំណាចអានិសង្សកឋិន ហើយភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់ ក៏ត្រូវនិស្សគ្គិយ បាចិត្តិយវៀរលែងតែបានសម្មតិអំពីសង្ឃ ។

៣-តតិយកឋិន កាលបើអស់អំណាចអានិសង្សកឋិនហើយ បើអកាល

ចីវរកើតឡើងដល់ភិក្ខុ. ភិក្ខុមានបំណងនឹងធ្វើចីវរ ប៉ុន្តែសំពត់ខ្វះធ្វើមិនគ្រាន់ បើមានបំណងនឹងរកថែមទៀត ឬថាមុខជានឹងបានទៀត គប្បីទុកសំពត់នោះយ៉ាងយូរបំផុត បានត្រឹម១ខែ. បើទុកឱ្យលើសពីនោះទៅ. ទុកជាមានសង្ឃឹមថា មុខជានឹង បានទៀត ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។

៤-បុរាណចីវរ ភិក្ខុប្រើភិក្ខុនី ដែលមិនមែនជាញាតិ ឱ្យលាងក្ដី ឱ្យជ្រលក់ ក្ដី. ឱ្យគក់ក្ដី នូវចីវរចាស់ ត្រូវនិស្សគ្គិយបាចិត្តិយ ។

៥-ចីវរប្បដិគ្គហណ ភិក្ខុទទួលចីវរអំពីដៃភិក្ខុនី ដែលមិនមែនជាញាតិ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបូរត្ថា ។

៦-អញ្ញាតកវិញ្ញត្តិ ភិក្ខុសូមចីវរអំពីគ្រហស្ថ ដែលមិនមែនជាញាតិ. បានមក ត្រូវនិស្សគ្គិយបាចិត្តិយ. វៀរលែងតែមានសម័យ គឺសម័យដែលភិក្ខុមានចីវរចោរ លួចទៅ ឬចីវរអន្តរាយដោយហេតុណាមួយ ។

៧-តទុត្តរិ ក្នុងសម័យនោះ ភិក្ខុត្រូវសូមបានតែស្បង់ និងចីពរប៉ុណ្ណោះឯង. បើសូមឱ្យលើសពីនោះ បានមក ត្រូវនិស្សគ្គិយបាចិត្តិយ ។

៨-បឋមុបក្ខដ បើគ្រហស្ថមិនមែនជាញាតិ គេនិយាយថា គេនឹងប្រគេនចីវរដល់ភិក្ខុឈ្មោះនេះ ភិក្ខុនោះនឹងបានដឹងហើយ ក៏ចូលទៅនិយាយឱ្យគេប្រគេនចីវរ. ដែលមានតំលៃល្អជាងកំណត់ដើម ដែលគេបំរុងប្រគេននោះ បានមក. ត្រូវនិស្សគ្គិយបាចិត្តិយ ។

៩-ចុតិយុបក្ខដ បើគ្រហស្ថដែលគេបំរុងប្រគល់ចីវរនោះ មានច្រើន នាក់ ដែលមិនមែនជាញាតិ. ភិក្ខុទៅនិយាយឱ្យគេរួមថ្លៃជាមួយគ្នា. ឱ្យទិញ ចីវរ ដែលមានតំលៃជាងកំណត់ដើម ដែលគេបំរុងប្រគេននោះ, បានមក ត្រូវនិស្សគ្គិយបាចិត្តិយ ។

១០-រាជ បើមានជនណាមួយ នាំយកតំលៃចីវរមក គេសួរភិក្ខុ ថា " អ្នកណាជាវេយ្យាវច្ចករបស់លោក ? " បើភិក្ខុត្រូវការចីវរក៏គប្បី ចង្អុលបង្ហាញឈ្មោះ វេយ្យាវច្ចករ ទោះបីញោមវត្តក្តី ឧបាសកក្តីថា " អ្នក នុ៎ះជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ " លុះគេប្រគេនថ្លៃចីវរ ដល់វេយ្យា វច្ចករនោះហើយ គេប្រាប់ថា " បើព្រះករុណាត្រូវការចីវរឱ្យចូលទៅឯវេយ្យា វច្ចករឈ្មោះនោះចុះ " ។ កាលបើភិក្ខុនោះ ត្រូវការចីវរ គប្បីទៅនិយាយ នឹងវេយ្យាវច្ចករនោះថា " អាត្មាត្រូវការចីវរ " ដូច្នេះបានត្រឹម ៣ ដង បើមិនបានចីវរទេ. ត្រូវទៅឈរស្ងៀមឱ្យល្មម គេមើលឃើញបានត្រឹម៦ដង ទៀត បើនៅតែមិនបាន ហើយទៅតឿនទារឱ្យលើស ពី៣ដង ទៅឈរ ស្ងៀម ឱ្យលើស៦ដង បានមកត្រូវនិស្សគ្គិយបាចិត្តិយ ។ បើបានទៅតឿនទារ· ព្រមទាំងបានទៅឈរស្ងៀមគ្រប់កំណត់ហើយ នៅតែមិនបានចីវរ, ត្រូវទៅ ប្រាប់ ឬប្រើបំរើឱ្យទៅប្រាប់ម្ចាស់ដើមវិញថា របស់នោះមិនសំរេចប្រយោជន៍ ដល់ខ្លួនទេ ឱ្យគេទៅទារយករបស់គេវិញចុះ ។

# កោសិយវគ្គទី ២

១-កោសិយ ភិក្ខុឱ្យគេធ្វើសន្ថតលាយដោយសូត្រត្រូវនិស្សគ្គិយបាចិត្តិយ

២-សុទ្ធកាឡក ភិក្ខុឱ្យគេធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធ ត្រូវនិស្សគ្គិយ-បាចិត្តិយ ។

៣-ទ្វេភាគ ភិក្ខុឱ្យគេធ្វើសន្ថតថ្មី គប្បីដាក់រោមចៀមខ្មៅពីរភាគ, ស-មួយភាគ, ក្រហមមួយភាគ ត្រូវជាបួនភាគ បើដាក់រោមខ្មៅឱ្យលើសជាងពីរភាគឡើងទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

៤-ឆព្វស្ស ភិក្ខុឱ្យគេធ្វើសន្ថតថ្មី ត្រូវប្រើប្រាស់ឱ្យបាន៦ឆ្នាំ, បើមិនទាន់ដល់៦ឆ្នាំ ហើយគេធ្វើសន្ថតថ្មីទៀត ត្រូវនិស្សគ្គិយបាចិត្តិយ, វៀរលែងតែបានសម្មតិ អំពីព្រះសង្ឃ ។

៥-និសីទនសន្ថត ភិក្ខុឱ្យគេធ្វើសន្ថតសំរាប់ទ្រាប់អង្គុយ, ត្រូវកាត់យកសន្ថតចាស់មួយចំអាមព្រះសុគតដោយជុំវិញ មកបញ្ចូលនឹងសន្ថតថ្មី ដើម្បីធ្វើឱ្យអន់ពណ៌ បើមិនធ្វើដូច្នេះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

៦-ឯឡកលោម ភិក្ខុដើរទៅកាន់ផ្លូវឆ្ងាយ, បើមានសេចក្តីត្រូវការដោយរោមចៀម ដែលគេប្រគេន ក៏គប្បីទទួលបាន, បើមិនមានគេនាំយកទៅឱ្យទេ គប្បីនាំទៅដោយខ្លួនឯងបានត្រឹម ៣យោជន៍, បើនាំឱ្យលើសពីកំណត់នោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

៧-ឯឡកលោមធោវាបនភិក្ខុប្រើនាងភិក្ខុនី ដែលមិនមែនជាញាតិ. ឱ្យលាងក្តី, ឱ្យជ្រលក់ក្តី, ឱ្យសិត ឬត្រដោះក្តី នូវរោមចៀម ត្រូវនិស្សគ្គិយបាចិត្តិយ ។

៨-រូបិយ ភិក្ខុទទួលខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យទទួលក្តី នូវមាស ឬប្រាក់, ឬត្រេកអរចំពោះមាសប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួនត្រូវនិស្សគ្គិយបាចិត្តិយ ។

៩-រូបិយសំវោហារ ភិក្ខុប្រព្រឹត្តិលក់ ទិញ ផ្លាស់ប្តូរដោយរូបិយៈ មានប្រការ ផ្សេងៗ ត្រូវនិស្សគ្គិយបាចិត្តិយ ។

១០-កយវិក្កយ ភិក្ខុប្រព្រឹត្តិលក់ ទិញ ផ្លាស់ប្តូររបស់មានប្រការផ្សេងៗ ត្រូវនិស្សគ្គិយបាចិត្តិយ ។

## បត្តវគ្គទី ៣

១-បត្ត ភិក្ខុទុកអតិរេកបាត្រយ៉ាងយូរបំផុតត្រឹម១០ថ្ងៃ, បើទុកឱ្យកន្លង ហួសពីនោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

២-ខុនបញ្ចពន្ធន ភិក្ខុមានបាត្រមានចំណាង គឺស្នាមប្រេះមិនទាន់ដល់ប្រាំអន្លើរ ហើយឱ្យគេទិញបាត្រថ្មីទៀតបានមក ត្រូវនិស្សគ្គិយបាចិត្តិយ ។

៣-ភេសជ្ជៈ ភិក្ខុទទួលប្រគេនភេសជ្ជៈ ៥ យ៉ាង គឺ ទឹកដោះគោរាវ, ទឹកដោះខាប់, ប្រេង, ទឹកឃ្មុំ, ស្ករអំពៅ ភេសជ្ជៈណាមួយ ត្រូវទុកយ៉ាងយូរបំផុតត្រឹម ៧ថ្ងៃ បើទុកឱ្យកន្លងហួសពីនោះ ទៅត្រូវនិស្សគ្គិយបាចិត្តិយ ។

៤-វស្សិកសាដិកា កាលជាខាងចុងនៃរដូវក្ដៅ១ ខែគឺពីថ្ងៃ១រោច ខែជេស្ឋ ទៅ ដល់ថ្ងៃខែដាច់ កន្លះខែនេះ ជាកាលត្រូវភិក្ខុស្វែងរកសំពត់សំរាប់ងូតទឹកភ្លៀង, ពីថ្ងៃ១ កើតខែអាសាឍ ទៅដល់ថ្ងៃពេញបូណ៌មី កន្លះខែនេះ ជាកាលត្រូវភិក្ខុស្វែង រកផងក៏បាន ធ្វើឱ្យសំរេចផងក៏បាន ស្លៀកផងក៏បាន, បើស្វែងរកហើយ ឬធ្វើឱ្យសំរេចក្នុងរវាងកន្លះខែខាងរនោច ខែជេស្ឋ (១) ត្រូវនិស្សគ្គិយបាចិត្តិយ ។

៥-ចីវរាច្ឆិន្នន ភិក្ខុបានឱ្យចីវរដល់ភិក្ខុឯទៀត ហើយក្រោធខឹងដណ្ដើមយកវិញក្ដី ដោយខ្លួនឯងក្ដី, ប្រើអ្នកដទៃឱ្យដណ្ដើមយកវិញក្ដី, បានមកត្រូវនិស្សគ្គិយ បាចិត្តិយ ។

៦-សុត្តវិញ្ញត្តិ ភិក្ខុសូមអំបោះដោយខ្លួនឯង យកមកឱ្យជាងតម្បាញត្បាញចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។

៧-មហាបេសការ បើគ្រហស្ថមិនមែនជាញាតិ ឱ្យជាងតម្បាញត្បាញចីវរ ដើម្បីប្រគេនភិក្ខុ, បើភិក្ខុនោះទៅនិយាយនឹងជាងតម្បាញឱ្យគេធ្វើឱ្យល្អឡើង នឹង ថែមរង្វាន់ឱ្យទៀត បានមក ត្រូវនិស្សគ្គិយបាចិត្តិយ ។

៨-អច្ចេកចីវរ នៅខ្វះ១០ថ្ងៃទៀត នឹងដល់ថ្ងៃពេញបូណ៌មី ខែអស្សុជ,

---

១- ពីថ្ងៃ ១រោចខែជេស្ឋ រៀងមកដល់ថ្ងៃខែដាច់ ក្នុងរវាងកន្លះខែនេះ បានតែខាងស្វែងរកតែប៉ុណ្ណោះ កុំអាលធ្វើឱ្យសំរេចឡើយ ។ ពីថ្ងៃ១កើត ខែអាសាឍ រៀងមកដល់ថ្ងៃ១៥កើត ត្រូវប្រព្រឹត្តិរាល់ទាំងស្វែងរក ទាំងធ្វើឱ្យហើយ ព្រមទាំងស្លៀកផងបាន ឥតទោស ។

ដែលជាខែទីបី នៃវស្សានរដូវ. បើ អរច្ចកចីវរ កើតឡើងដល់ភិក្ខុ. ភិក្ខុសំគាល់ថាជា អរច្ចកចីវរ. គប្បីទទួលទុកបាន លុះទទួលហើយ គប្បីទុកដាក់ដរាបដល់អស់ សម័យចីវរកាល. បើទុកឱ្យយូរហួសកំណត់នោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

៩-សាសង្ក ភិក្ខុនៅចាំវស្សាក្នុងសេនាសនៈ ក្នុងព្រៃដែលជាទីមានរង្កៀស មានភ័យ. លុះចេញវស្សាហើយ. បើត្រូវការនឹងទុកត្រៃចីវរណាមួយក្នុងស្រុក. កាលបើមានហេតុ ត្រូវទុកបានយ៉ាងយូរបំផុតត្រឹម ៦ រាត្រី បើទុកឱ្យលើស កំណត់នោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានសម្មតិអំពីព្រះសង្ឃ។

១០-បរិណត ភិក្ខុកាលបើដឹងហើយបង្អោនសង្ឃលាភមក ដើម្បីខ្លួនវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។

## សុទ្ធិកបាចិត្តិយ ៩២

សុទ្ធិកបាចិត្តិយ ៩២ ចែកចេញជាវគ្គមាន ៩ គឺ មុសាវាទវគ្គ១, ភូតគាម-វគ្គ១, ឱវាទវគ្គ១, ភោជនវគ្គ១, អចេលកវគ្គ១, សុរាបានវគ្គ១, សប្បាណក-វគ្គ១, សហធម្មិកវគ្គ១ ។

ក្នុងវគ្គមួយៗ មានសិក្ខាបទដប់ៗ វៀរលែងតែ សហធម្មិកវគ្គមួយមាន សិក្ខាបទ១២ ។

# មុសាវាទវគ្គ ទី ១

១-មុសាវាទ  ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួន  ត្រូវបាចិត្តិយ ។

២-ឱមសវាទ  ភិក្ខុពោលពាក្យចាក់ដោតភិក្ខុផងគ្នា  ត្រូវបាចិត្តិយ ។

៣-បេសុញ្ញ  ភិក្ខុញុះញង់ភិក្ខុផងគ្នា  ត្រូវបាចិត្តិយ ។

៤-បទសោធម្ម ភិក្ខុបង្រៀនធម៌ជាបទចំពោះអនុបសម្បន្នត្រូវបាចិត្តិយ ។

៥-បឋមសហសេយ្យ ភិក្ខុដេកជាមួយគ្នា  និងអនុបសម្បន្នឱ្យលើសជាង ២ ឬ៣ យប់ឡើងទៅ  ត្រូវបាចិត្តិយ ។

៦-ទុតិយសហសេយ្យ ភិក្ខុដេកជាមួយគ្នា  និងមាតុគ្រាម  ត្រូវបាចិត្តិយ ។

៧-ធម្មទេសនា ភិក្ខុសំដែងធម៌ចំពោះមាតុគ្រាមឱ្យលើសជាង៦ ម៉ាត់ឡើងទៅ  ត្រូវបាចិត្តិយ, វៀរលែងតែមានបុរសដឹងក្តីនៅជាមួយផង ។

៨-ភូតារោចន  ភិក្ខុប្រាប់ឧត្តរិមនុស្សធម្មដែលខ្លួនបានពិតមែនដល់អនុបសម្បន្ន  ត្រូវបាចិត្តិយ ។

៩-ទុដ្ឋុល្លារោចន  ភិក្ខុប្រាប់ទុដ្ឋុល្លាបត្តិដល់អនុបសម្បន្ន  ត្រូវបាចិត្តិយ វៀរលែងតែបានសម្មតិអំពីសង្ឃ ។

១០-បឋវីខណន  ភិក្ខុជីកដោយខ្លួនឯងក្តី  ប្រើអ្នកដទៃឱ្យជីកក្តី  នូវផែនដី ត្រូវបាចិត្តិយ ។

# ភូតគាមវគ្គ ទី ២

១-ភូតគាម ភិក្ខុធ្វើភូតគាមឱ្យវិនាស ត្រូវបាចិត្តិយ ។

២-អញ្ញវាទក ភិក្ខុពោលពាក្យដទៃ ឬ ធ្វើឱ្យសង្ឃបានសេចក្តីលំបាក ត្រូវបាចិត្តិយ ។

៣-ឧជ្ឈាបនក ភិក្ខុបង្គាប់ភិក្ខុឯទៀត ឱ្យពោលទោសភិក្ខុផងគ្នា ឬតិះដៀលភិក្ខុផងគ្នាខ្លួនឯង ត្រូវបាចិត្តិយ ។

៤-បឋមសេនាសន ភិក្ខុយកគ្រែក្តី តាំងក្តី ពូកក្តី [1] ជារបស់សង្ឃទៅតាំងទុកនៅទីវាលហើយ កាលចៀសចេញទៅចាកទីនោះ, មិនយកទៅទុក ដាក់ដោយខ្លួនឯងក្តី, មិនប្រើអ្នកដទៃឱ្យយកទៅទុកដាក់ក្តី, ចៀសចេញទៅ ត្រូវបាចិត្តិយ ។

៥-ទុតិយសេនាសន ភិក្ខុយកកំរាលជារបស់សង្ឃមកក្រាលដេកក្នុងកុដិជារបស់សង្ឃ, កាលនឹងចៀសចេញទៅចាកទីនោះ មិនយកទៅទុកដាក់ដោយខ្លួនឯងក្តី មិនប្រើអ្នកដទៃឱ្យយកទៅទុកដាក់ក្តី ចៀសចេញទៅ, ត្រូវបាចិត្តិយ ។

៦-អនុប្បខជ្ជ ភិក្ខុដឹងថាកុដិជារបស់សង្ឃ មានភិក្ខុចូលទៅនៅមុន, ហើយក្លែងយកកំរាលទៅក្រាលដេក, ហើយបានអង្គុយឬដេកជ្រៀត

---

(១)- ពូកដែលធ្វើប្រើប្រាស់តាមពុទ្ធានុញ្ញាត (មើលតូលោនទ្ធសិក្ខាបទទី៦ ក្នុងរតនវគ្គទី៩)

បៀតក្នុងទីនោះ ដើម្បីនឹងឱ្យភិក្ខុដែលនៅមុននោះ មានសេចក្ដីចង្អៀតចង្អល់ទញ់ទាល់ចិត្ត ហើយនឹងចៀសចេញទៅ ត្រូវបាចិត្តិយ ។

៧-និក្កឌ្ឍន ភិក្ខុក្រោធខឹងនឹងភិក្ខុផងគ្នា ហើយបណ្ដេញខ្លួនឯងក្ដី ប្រើឱ្យគេបណ្ដេញក្ដី ឱ្យចេញចាកកុដិជារបស់សង្ឃ. ត្រូវបាចិត្តិយ ។

៨-វេហាសកុដិ ភិក្ខុអង្គុយក្ដី ដេកក្ដី លើគ្រែ ឬតាំងដែលមានជើងគេគ្រាន់តែផ្ដុំទុក នៅមិនទាន់បានបោះកន្លាស់ ឬនៅមិនទាន់បានចងរួតរឹតឱ្យណែន ដែលគេដាក់តំកល់នៅលើធ្នើរ សំរាប់ទើរវត្ថុក្នុងកុដិ. ត្រូវបាចិត្តិយ ។

៩-មហល្លក ភិក្ខុនឹងយកដី ឬកំបោរបូកកុដិ គប្បីបូកយ៉ាងច្រើនបំផុតត្រឹម ៣ជាន់. បើបូកឱ្យលើសជាង ៣ជាន់ឡើងទៅ. ត្រូវបាចិត្តិយ ។

១០-សប្បាណក ភិក្ខុដឹងថា ទឹកមានសត្វរស់. ហើយយកទៅស្រោចខ្លួនឯង ឬប្រើគេឱ្យចាក់ស្រោចនូវស្មៅ ឬដី. ត្រូវបាចិត្តិយ ។

## វាទវគ្គទី ៣

១-ភិក្ខុនោវាទ ភិក្ខុដែលសង្ឃមិនបានសន្មត ហើយពោលប្រដៅភិក្ខុនី. ត្រូវបាចិត្តិយ ។

២-អត្ថង្គត ភិក្ខុដែលសង្ឃបានសន្មតហើយ. កាលបើព្រះអាទិត្យអស្តង្គទៅហើយ. ពោលប្រដៅភិក្ខុនី ត្រូវបាចិត្តិយ ។

៣-ភិក្ខុនូបស្សយ ភិក្ខុចូលទៅពោលប្រដៅភិក្ខុនីដល់ទីលំនៅ. ត្រូវ

បាចិត្តិយ វៀរលែងតែភិក្ខុនី ដែលមានជំងឺ ។

៤-អាមិស ភិក្ខុតិះដៀលភិក្ខុឯទៀតថា ភិក្ខុទាំងឡាយ ប្រដៅភិក្ខុនី ព្រោះហេតុតែអាមិស. ត្រូវបាចិត្តិយ ។

៥-ចីវរទាន ភិក្ខុឱ្យចីវរដល់ភិក្ខុនីដែលមិនមែនជាញាតិ. ត្រូវបាចិត្តិយ វៀរលែងតែប្ដូរគ្នា ។

៦-ចីវរសិព្វន ភិក្ខុដេរដោយខ្លួនឯងក្ដី ប្រើអ្នកឯទៀតឱ្យដេរឱ្យក្ដី នូវចីវររបស់ភិក្ខុនីដែលមិនមែនជាញាតិ. ត្រូវបាចិត្តិយ ។

៧-សំវិធាន ភិក្ខុបបួលភិក្ខុនី ដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា សូម្បីតែចន្លោះស្រុកមួយ ក៏ត្រូវបាចិត្តិយ. វៀរលែងតែផ្លូវដែលមានរង្កៀស មានភ័យផ្សេងៗ ។

៨-នាវាភិរូហណ ភិក្ខុបបួលភិក្ខុនីជិះទូកមួយជាមួយគ្នា ទៅច្រាសទឹកក្ដី បណ្ដោយទឹកក្ដី. ត្រូវបាចិត្តិយ វៀរលែងតែជិះឆ្លងទទឹង ។

៩-បរិពាចន ភិក្ខុដឹងហើយឆាន់ចង្ហាន់បិណ្ឌបាត ដែលភិក្ខុនីចាត់ចែង. ត្រូវបាចិត្តិយ វៀរលែងតែចង្ហាន់ ដែលគ្រហស្ថគេផ្ដើមឡើងជាមុន ។

១០-រហោនិសជ្ជ ភិក្ខុអង្គុយ (ឬដេក) ក្នុងទីកំបាំងតែពីរនាក់នឹងភិក្ខុនី . ត្រូវបាចិត្តិយ ។

# ភោជនវគ្គ ទី ៤

១-អាវសថបិណ្ឌ ភិក្ខុមិនមានជំងឺ ត្រូវឆាន់អាវសថបិណ្ឌបាត[១] បានតែម្តង, បើឆាន់ឱ្យលើសពីកំណត់នោះទៅ, ត្រូវបាចិត្តិយ ។

២-គណភោជន ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះទទួលគណភោជនព្រមគ្នា វៀរ លែងតែមានសម័យ គឺសម័យដែលមានជំងឺ១, សម័យដែលគេឱ្យចីវរ១, សម័យដែលធ្វើចីវរ១, សម័យដែលដើរផ្លូវឆ្ងាយ១, សម័យដែលឡើងជិះទូក១, សម័យដែលមានភិក្ខុច្រើនរូប១, សម័យនៃសមណភត្ត១ ។

៣-បរម្បរភោជន ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន, វៀរលែង តែមានសម័យ គឺ សម័យដែលមានជំងឺ១, សម័យដែលគេឱ្យចីវរ១, សម័យដែលគេធ្វើចីវរ១ ។

៤-កាណមាតា បើទាយកបវារណាភិក្ខុ ដែលចូលទៅកាន់ត្រកូល, ដោយនំក្តី ដោយសត្តុវក្តី, ដើម្បីឱ្យនាំទៅបានតាមប្រាថ្នា, ភិក្ខុមានសេចក្តីត្រូវការ ត្រូវទទួលត្រឹមពេញពីរ ឬបីបាត្របាន, បើទទួលឱ្យលើសពីកំណត់នោះទៅ, ត្រូវបាចិត្តិយ ។ នំ ឬ សត្តុវដែលបានច្រើនមកនោះ ត្រូវភិក្ខុរំលែកចែកឱ្យភិក្ខុឯទៀត ឆាន់ផងទើបគួរ ។

---

១-ភោជនាហារជាទាន ដែលគេចាត់ចែងក្នុងរោងជាដើម មិនចំពោះបុគ្គលណា១ គេឱ្យជាទានត្រឹមតែមួយពេលព្រឹក ហៅថា អាវសថបិណ្ឌ : ឬ អាវសថបិណ្ឌបាត ។

៥-បឋមប្បវារណា ភិក្ខុឆាន់ហើយ បានហាមភោជនហើយទំពាស៊ីក្ដី បរិភោគ នូវខាទនីយាហារ ឬភោជនីយាហារដែលជា អនតិរិត្តៈ ត្រូវបាចិត្តិយ ។

៦-ទុតិយប្បវារណា ភិក្ខុណាមួយ នាំភត្តទៅបវារណា បង្ខំភិក្ខុដែលឆាន់ហើយ ហាមភោជនហើយ ដោយខាទនីយាហារ ឬភោជនីយាហារ ដែលជា អនតិរិត្តៈ នោះ, ភិក្ខុនោះ ត្រូវបាចិត្តិយ ។

៧-វិកាលភោជន ភិក្ខុឆាន់ខាទនីយាហារ ឬភោជនីយាហារ ក្នុងវេលាវិកាល ត្រូវបាចិត្តិយ ។

៨-សន្និធិការក ភិក្ខុឆាន់ខាទនីយាហារ ឬភោជនីយាហារ ដែលខ្លួនទុកដាក់ឱ្យកន្លងរាត្រី ត្រូវបាចិត្តិយ ។

៩-បណីតភោជន ភិក្ខុមិនមានជំងឺ, សូមបណីតភោជ ៩ យ៉ាងគឺ ទឹកដោះរាវ១, ទឹកដោះខាប់១, ប្រេង១, ទឹកឃ្មុំ១, ស្ករអំពៅ១, ត្រី១, សាច់១, ទឹកដោះស្រស់១, ទឹកដោះជូរ១, វត្ថុណាមួយ អំពីគ្រហស្ថ ដើម្បីជា ប្រយោជន៍ដល់ខ្លួនហើយឆាន់, ត្រូវបាចិត្តិយ ។

១០-ទន្តបោណ ភិក្ខុឆាន់អាហារដែលមិនបានទទួលប្រគេន ត្រូវបាចិត្តិយ, វៀរលែងតែទឹកសុទ្ធ និងឈើស្ទន់ ។

## អចេលកវគ្គទី ៥

១-អចេលក ភិក្ខុឱ្យខាទនីយាហារ ឬភោជនីយាហារ ដល់អចេលកក្តី បរិព្វាជកក្តី ដោយដៃរបស់ខ្លួន. ត្រូវបាចិត្តិយ ។

២-ឧយ្យោជន ភិក្ខុបបួលភិក្ខុដទៃទៅបិណ្ឌបាតជាមួយគ្នា. គិតនឹងប្រព្រឹត្តិអនាចារ ហើយបណ្ដេញភិក្ខុនោះឱ្យត្រឡប់មកវិញ. ត្រូវបាចិត្តិយ ។

៣-សភោជន ភិក្ខុរុករានចូលទៅអង្គុយក្នុងត្រកូលដែលមានតែពីរនាក់ គឺប្ដី និងប្រពន្ធ [1] . ត្រូវបាចិត្តិយ ។

៤-រហោបដិច្ឆន្ន ភិក្ខុសំរេចការអង្គុយលើអាសនៈ ជាទីស្ងាត់កំបាំងជាមួយនឹង មាតុគ្រាម. ត្រូវបាចិត្តិយ ។

៥-រហោនិសជ្ជ ភិក្ខុសំរេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាម តែម្នាក់នឹងម្នាក់. ត្រូវបាចិត្តិយ ។

៦-ចារិត្ត ភិក្ខុបានទទួលនិមន្តគេហើយ ឈ្មោះថាជាអ្នកមានភត្តហើយ. មិនបានលា ឬប្រាប់ភិក្ខុផងគ្នា ដែលមាននៅហើយត្រាច់ទៅក្នុងត្រកូល ទាំងឡាយក្នុងពេលមុនភត្តក្ដី ក្រោយភត្តក្ដី. ត្រូវបាចិត្តិយ. វៀរលែងតែមាន សម័យគឺ សម័យដែលគេឱ្យចីវរ១. សម័យដែលធ្វើចីវរ១ ។

---

១-ទោះបីគេកំពុងបរិភោគភោជន ក៏ពុំគួរចូលទៅអង្គុយក្បែរគេពាក់ពាកចិត្ត ឬ ក្បែរគេរៀនរកាត់ឡើយ ។ នេះជាសណ្ដាប់ធ្នាប់របស់សាធារណជន អ្នកមានចរិយាល្អ សូម្បីមិនជាបព្វជិតក៏ដោយ ។

៧-បហានាប បើគេបវារណាដោយបច្ច័យ៤ កំណត់ត្រឹម៤ខែ ភិក្ខុគប្បី សូមគេបានតែត្រឹមកំណត់នោះប៉ុណ្ណោះ. បើសូមឱ្យលើសកំណត់នោះទៅ. ត្រូវបាចិត្តិយ. វៀរលែងតែគេបានបវារណាថែមទៀត ឬគេបានបវារណាជានិច្ច ។

៨-ឧយ្យុត្ត ភិក្ខុទៅដើម្បីមើលកងទ័ព ដែលគេលើកចេញទៅ. ត្រូវបាចិត្តិយ វៀរលែងតែមានហេតុ ។

៩-សេនាវាស បើភិក្ខុនោះមានហេតុអ្វីមួយដែលគួរនឹងទៅ គប្បីនៅក្នុងកងទ័ពបានត្រឹមពីរ ឬ បីរាត្រី. បើនៅឱ្យលើសពីកំណត់នោះទៅ. ត្រូវបាចិត្តិយ ។

១០-ឧយ្យោធិក កាលបើភិក្ខុនៅក្នុងកងទ័ព តាមកំណត់នោះ ទៅកាន់ទីដែលគេច្បាំងគ្នាក្តី ទីដែលគេត្រួតពលក្តី, ទីដែលគេចាត់ក្បួនទ័ពក្តី មើលពួកសេនាដែលគេរៀបក្បួនទ័ពហើយក្តី. ត្រូវបាចិត្តិយ ។

## សុរាបានវគ្គ ទី ៦

១-សុរាបាន ភិក្ខុផឹកសុរា និងមេរ័យ. ត្រូវបាចិត្តិយ ។

២-អង្គុលិបតោទក ភិក្ខុចាក់ក្រឡេកប្រឡែងគ្នាដោយជន្លួញ គឺម្រាមដៃ. ត្រូវបាចិត្តិយ ។

៣-ហាសធម្ម ភិក្ខុលេងទឹក. ត្រូវបាចិត្តិយ ។

៤-អនាទរិយ ភិក្ខុសំដែងសេចក្ដីមិនអើពើ, ត្រូវបាចិត្តិយ ។

៥-ភីសាបន ភិក្ខុពញាក់ ឬបន្លាចភិក្ខុផងគ្នា, ត្រូវបាចិត្តិយ ។

៦-ជោតិសមាធហន ភិក្ខុមិនមានជំងឺ បង្កាត់ភ្លើងខ្លួនឯងក្ដី ប្រើអ្នកដទៃឱ្យបង្កាត់ក្ដី, ដើម្បីនឹងអាំង, ត្រូវបាចិត្តិយ វៀរលែងតែមានហេតុ ។

៧-នហាន ភិក្ខុ (នៅក្នុងមជ្ឈិមប្រទេស), បើមិនទាន់ដល់កន្លះខែ ហើយងូតទឹក, ត្រូវបាចិត្តិយ វៀរលែងតែមានសម័យ ។

៨-ទុព្វណ្ណករណា ភិក្ខុបានចីវរថ្មីមកហើយ, បើត្រូវការប្រើប្រាស់, គប្បីធ្វើពិន្ទុ ដោយពណ៌ ៣ យ៉ាង គឺ ពណ៌ខៀវ១, ពណ៌ភក់១, ពណ៌ខ្មៅជាំ១, ពណ៌ណាមួយសិន, បើមិនធ្វើពិន្ទុ ហើយប្រើប្រាស់, ត្រូវបាចិត្តិយ ។

៩-វិកប្បន ភិក្ខុបានវិកប្បចីវរដោយខ្លួនឯងចំពោះភិក្ខុក្ដី, ភិក្ខុនីក្ដី, សិក្ខមានាក្ដី, សាមណេរក្ដី, សាមណេរីក្ដី, អ្នកទទួលវិកប្បមិនបានដកវិកប្បឱ្យសិន ស្រាប់តែយកចីវរនោះមកប្រើប្រាស់, ត្រូវបាចិត្តិយ ។

១០-អបនិធាន ភិក្ខុលាក់ខ្លួនឯង ឬប្រើគេឱ្យលាក់ នូវបរិក្ខារ គឺបាត្រក្ដី, ចីវរ ក្ដី, និសីទនៈក្ដី, បំពង់ម្ជុលក្ដី, វត្ថពន្ធចង្កេះក្ដី របស់ភិក្ខុផងគ្នា ដោយមាន បំណងនឹងលេងសើច, ត្រូវបាចិត្តិយ ។

## សប្បាណកវគ្គ ទី ៧

១-សញ្ចិច្ចបាណា ភិក្ខុក្លែងសំលាប់សត្វមានជីវិត, ត្រូវបាចិត្តិយ ។

២-សប្បាណក ភិក្ខុកាលដឹងថា ទឹកមានសត្វរស់ ហើយប្រើប្រាស់ទឹកនោះ, ត្រូវបាចិត្តិយ ។

៣-ឧក្កោដន ភិក្ខុ កាលដឹងថា អធិករណ៍ដែលសង្ឃបានរំងាប់ដោយត្រឹមត្រូវតាមធម៌ហើយ, ត្រឡប់សើរើជាថ្មីវិញ, ត្រូវបាចិត្តិយ ។

៤-ទុដ្ឋុល្លប្បដិច្ឆាទន ភិក្ខុកាលដឹងហើយ បិទបាំងទុកនូវ ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា, ត្រូវបាចិត្តិយ ។

៥-ឩនវីសតិវស្ស ភិក្ខុកាលដឹងហើយឱ្យឧបសម្បទាដល់បុគ្គល ដែលមានអាយុមិនទាន់គ្រប់ ២០ឆ្នាំ, ត្រូវបាចិត្តិយ ។

៦-ថេយ្យសត្ថ ភិក្ខុកាលដឹងហើយបបួលពួកឈ្មួញជាចោរ ដើរទៅកាន់ផ្លូវឆ្ងាយ មួយជាមួយគ្នា ដោយហោចទៅ សូម្បីតែចន្លោះស្រុកមួយ, ត្រូវបាចិត្តិយ ។

៧-សំវិធាន ភិក្ខុបបួលមាតុគ្រាមដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា ដោយហោចទៅ សូម្បីតែចន្លោះស្រុកមួយ, ត្រូវបាចិត្តិយ ។

៨-អរិដ្ឋ ភិក្ខុប្រកាន់ទិដ្ឋិ បាបខុសចាកធម៌វិន័យ, ភិក្ខុឯទៀតហាមប្រាមមិនស្តាប់, សង្ឃបានសូត្រសមនុភាសនកម្ម ចប់អនុស្សាវនាគំរប់៣ ហើយ, នៅតែមិនលះបង់, ត្រូវបាចិត្តិយ ។

៩-ឧក្ខិត្តសម្ភោគ ភិក្ខុដឹងថា ភិក្ខុនោះមិនទាន់លះបង់ទិដ្ឋិបាប, ហើយបរិភោគរួមក្តី នៅរួមក្តី សំរេចការដេករួមក្តី, ត្រូវបាចិត្តិយ ។

១០-កណ្ដក ភិក្ខុដឹងថាសាមណេរដែលភិក្ខុឯទៀត ឱ្យវិនាសហើយព្រោះ ទោសដែលឃើញខុសចាកធម៌វិន័យ, ហើយប្រលោមសាមណេរនោះឱ្យមក បំរើខ្លួនក្តី, រួមបរិភោគក្តី សំរេចការដេកជាមួយគ្នាក្តី, ត្រូវបាចិត្តិយ ។

## សហធម្មិកវគ្គ ទី ៨

១-សហធម្មិកភិក្ខុប្រព្រឹត្តិអនាចារ, ភិក្ខុឯទៀតដាស់តឿន, ក៏និយាយប្រកែកថា " ខ្ញុំព្រះករុណាមិនទាន់សិក្សាសិក្ខាបទនេះទេ ចាំសាកសួរលោកអ្នកចេះដឹងអ្នកទ្រទ្រង់វិន័យសិន " ពោលពាក្យដូច្នេះ, ត្រូវបាចិត្តិយ ។

២-វិលេខន ភិក្ខុដទៃកំពុងសំដែងបាតិមោក្ខ, ភិក្ខុនិយាយយ៉ាងនេះថា " ប្រយោជន៍អ្វីដោយសិក្ខាបទតូចតាច ដែលសំដែងហើយទាំងនេះ, សិក្ខា បទទាំងនេះ ប្រព្រឹត្តិទៅគ្រាន់តែដើម្បីសេចក្តីក្តៅក្រហាយចិត្ត សេចក្តីលំបាកចិត្ត និងសេចក្តីរសេមរសាមចិត្តប៉ុណ្ណោះឯង " ត្រូវបាចិត្តិយ ។

៣-មោហាន ភិក្ខុណាមួយ កាលបើភិក្ខុឯងទៀតកំពុងសំដែងបាតិមោក្ខ.
ពោលយ៉ាងនេះថា " ខ្ញុំទើបតែនឹងដឹងអម្បាញ់មិញនេះឯងថា សេចក្តីនេះមានក្នុងបាតិមោក្ខ " បើភិក្ខុឯទៀត ដឹងថាភិក្ខុនោះធ្លាប់ដឹងមកពីមុនហើយ តែពោលដូច្នេះ គឺក្លែងធ្វើពើជាមិនដឹងទៅទេ, សង្ឃគប្បីសូត្យប្រកាសមោ ហារោបនកម្ម, កាលបើសង្ឃសូត្យកម្មនោះចប់ហើយ, នៅតែក្លែងពើដូច្នោះទៀត, ត្រូវបាចិត្តិយ ។

៤-បហារទាន ភិក្ខុក្រោធខឹងហើយប្រហារភិក្ខុផងគ្នា, ត្រូវបាចិត្តិយ

៥-តលសត្តិក ភិក្ខុក្រោធខឹង ហើយងារឡើងនូវលំពែង គឺបាតដៃសំដៅ ភិក្ខុផងគ្នា, ត្រូវបាចិត្តិយ ។

៦-អមូលក ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឃាទិសេស មិនមានមូល, ត្រូវបាចិត្តិយ ។

៧-សញ្ចិច្ច ភិក្ខុក្លែងបង្កហេតុ ឱ្យមានសេចក្តីរង្កៀសសង្ស័យដល់ភិក្ខុផងគ្នា សូម្បីតែមួយស្របក់, ត្រូវបាចិត្តិយ ។

៨-ឧបស្សុតិ កាលបើភិក្ខុទាំងឡាយកំពុងវិវាទទាស់ទែងគ្នា, ភិក្ខុទៅលបចាំ ស្តាប់ដោយគិតថា គេនិយាយពាក្យណាអញនឹងស្តាប់ពាក្យនោះ ហើយមាន បំណងនឹងចោទផង, ត្រូវបាចិត្តិយ ។

៩-កម្មប្បដិពាហន ភិក្ខុបានឱ្យឆន្ទៈ ដើម្បីកម្មទាំងឡាយដែលប្រកប ដោយធម៌ហើយ, ដល់មកខាងក្រោយត្រឡប់តិះដៀលវិញ, ត្រូវបាចិត្តិយ

១០-បក្កមន កាលបើសង្ឃកំពុងប្រជុំគ្នាវិនិច្ឆ័យអធិករណ៍, ភិក្ខុមិនឱ្យឆន្ទៈ ហើយក្រោកចាកអាសនៈចៀសចេញទៅ, ត្រូវបាចិត្តិយ ។

១១-ខីយធម្ម ភិក្ខុព្រមព្រៀងជាមួយនឹងសង្ឃបានឱ្យចីវរដល់ភិក្ខុរូបណាមួយហើយ, លុះមកខាងក្រោយ ត្រឡប់តិះដៀលថាការឱ្យនោះគឺដោយយល់មុខ ត្រូវបាចិត្តិយ ។

១២-បរិណាមន ភិក្ខុដឹងហើយបង្អោនលាភ ដែលគេបំរុងនឹងប្រគេនសង្ឃ ត្រឡប់មកដើម្បីបុគ្គលវិញ, ត្រូវបាចិត្តិយ ។

## រតនវគ្គ ទី ៩

១-អន្តេបុរ ភិក្ខុមិនបានទទួលព្រះរាជានុញ្ញាតិជាមុន ហើយចូលទៅក្នុងល្វែងក្រឡាបន្ទំ ដែលព្រះមហាក្សត្រមុទ្ធាភិសិត្តរាជ កំពុងគង់នៅជាមួយនឹងព្រះមហេសី, ត្រូវបាចិត្តិយ ។

២-រតន ភិក្ខុរើខ្លួនឯង ឬប្រើគេឱ្យរើស នូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី, ត្រូវបាចិត្តិយ, វៀរលែងតែក្នុងវត្ត ឬក្នុងទីនៅអាស្រ័យ ដែលភិក្ខុត្រូវរើសទុកឱ្យគេផង ។

៣-ឧិកាលគាមប្បវេសន ភិក្ខុមិនបានលាភិក្ខុផងគ្នា ដែលមាននៅ. ហើយចូលទៅកាន់ស្រុកក្នុងវេលាវិកាល. ត្រូវបាចិត្តិយ វៀរលែងតែមានកិច្ចប្រញាប់ប្រញាប់ ។

៤-សូចិឃរ ភិក្ខុឱ្យគេធ្វើបំពង់ម្ជុលជាវិការៈនៃឆ្អឹងក្តី ជាវិការនៃភ្លុក ជាវិការនៃស្នែងក្តី. ត្រូវបាឆេទនកចិត្តិយ ។

៥-មញ្ច ភិក្ខុឱ្យគេធ្វើគ្រែថ្មីក្តី តាំងថ្មីក្តី. គប្បីធ្វើឱ្យមានជើងកំពស់ត្រឹម៨ធ្នាប់ ដោយធ្នាប់ព្រះសុគត. បើធ្វើឱ្យលើសពីកំណត់នោះទៅ. ត្រូវឆេទនកបាចិត្តិយ ។

៦-តូលោនទ្ធ ភិក្ខុឱ្យគេធ្វើគ្រែក្តី តាំងក្តី ញាត់ដោយគរ ឬសំឡី. ត្រូវឧទាឡនកបាចិត្តិយ ។

៧-និសីទន ភិក្ខុឱ្យគេធ្វើសំពត់និសីទនៈ គប្បីឱ្យគេធ្វើឱ្យត្រូវនឹងប្រមាណ គឺបណ្តោយ២ចំអាម ទទឹង១ចំអាមកន្លះ ជាយ១ចំអាម ដោយចំអាមព្រះសុគត. បើធ្វើឱ្យកន្លងហួសពីនោះទៅ. ត្រូវឆេទនកបាចិត្តិយ ។

៨-កណ្ឌុប្បដិច្ឆាទិ ភិក្ខុឱ្យគេធ្វើសំពត់សំរាប់គ្របបូស ឬកម[1] គប្បីឱ្យគេធ្វើឱ្យត្រូវនឹងប្រមាណ គឺបណ្តោយ ៤ចំអាម ទទឹង ២ចំអាម ដោយចំអាមព្រះសុគត.បើធ្វើ[ឱ្យ]កន្លងហួសពីនោះទៅ. ត្រូវឆេទនកបាចិត្តិយ

១-ទោះបូសទ្រមិចក្តី. បូសធំក្តី. កមក្តី. ដំបៅក្តី អាពាធណាមួយដែលមានទឹករងៃក្តី អាចប្រើសំពត់នេះបានទាំងអស់ ។

៩-ឧស្សិកសាដិកា ភិក្ខុឱ្យគេធ្វើសំពត់សំរាប់ងូតទឹកភ្លៀង គប្បីឱ្យគេធ្វើឱ្យត្រូវ នឹងប្រមាណ គឺបណ្ដោយ ៦ចំអាម ទទឹង ២ចំអាម កន្លះ ដោយចំអាមព្រះសុគត. បើធ្វើឱ្យកន្លងហួសពីនោះទៅ. ត្រូវឆេទនកបាចិត្តិយ ។

១០-នន្ទ ភិក្ខុឱ្យគេធ្វើចីវរប៉ុនចីវរព្រះសុគត ឬធំជាង, ត្រូវឆេទនកបាចិត្តិយ. ឯចីវរព្រះសុគតនោះ គឺបណ្ដោយ ៩ចំអាម ទទឹង ៦ចំអាម ដោយចំអាមព្រះសុគត ។

## បាដិទេសនីយ ៤

១-ហត្ថតោ បដិគ្គហណា ភិក្ខុទទួលខាទនីយភោជនីយាហារអំពីដៃភិក្ខុនី មិនមែនជាញាតិដែលចូលទៅកាន់ចន្លោះផ្ទះ ដោយដៃខ្លួនឯងមកបរិភោគ, ត្រូវបាដិទេសានីយ ។

២-កុលេសុ និមន្តិត ភិក្ខុកំពុងឆាន់. បើមានភិក្ខុនីមកហៅហៅឱ្យគេយក របស់នេះរបស់នោះប្រគេនភិក្ខុ, ភិក្ខុគប្បីបណ្ដេញភិក្ខុនីនោះចេញ. បើមិនបណ្ដេញចេញទេ, ត្រូវបាដិទេសានីយ ។

៣-សេក្ខសម្មត ភិក្ខុមិនមានជំងឺ, ទទួលខាទនីយភោជនីយាហារអំពីត្រកូលដែលសង្ឃសន្មតថាជាសេក្ខត្រកូលហើយ. ដែលគេឥតបាន

និមន្តឡើយ យកមកបរិភោគ. ត្រូវបាដិទេសានីយ ។

៤-អារញ្ញកសេនាសន  ភិក្ខុនៅក្នុងសេនាសនៈក្នុងព្រៃដែលជាទីមានរង្កៀស មានភ័យ. បើមិនមានជំងឺទេ. ទទួលខាទនីយភោជនីយាហារ អំពីទាយក ដែលគេមិនបានឱ្យដំណឹងជាមុន, ដោយដៃខ្លួនឯងមកបរិភោគ. ត្រូវបាដិទេសនីយ ។

## សេក្ខិយធម្ម ៧៥

វត្ថុដែលបព្វជិតត្រូវសិក្សា ឈ្មោះថាសេក្ខិយវត្ថុ ១ នេះចែកចេញជា ៤ពួក គឺ ពួកទី១ ឈ្មោះ សារុប្ប, ពួកទី២ ឈ្មោះ ភោជនប្បដិសំយុត្ត, ពួកទី៣ ឈ្មោះ ធម្មទេសនាបដិសំយុត្ត. ពួកទី៤ ឈ្មោះ បកិណ្ណក ។

# សារុប្បធីរ មាន ២៦

១-២ បព្វជិតគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹង { ស្លៀក / ដណ្តប់ } ឱ្យជាបរិមណ្ឌល គឺស្លៀកស្បង់គ្រងចីពរឱ្យត្រឹមត្រូវ [១] ។

៣-៤ បព្វជិតគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងបិទបាំងកាយ គឺឃ្លុំឱ្យត្រឹមត្រូវ { ដើរទៅ / អង្គុយនៅ } ក្នុងចន្លោះផ្ទះ [២] ។

៥-៦ ។ល។ អាត្មាអញនឹងសង្រួមឱ្យល្អ { ដើទៅ / អង្គុយនៅ } ក្នុងចន្លោះផ្ទះ ។

៧-៨ ។ល។ អាត្មាអញនឹងមានភ្នែកសំឡឹងចុះក្រោម { ដើទៅ / អង្គុយនៅ } ក្នុងចន្លោះផ្ទះ ។

៩-១០ ។ល។ អាត្មាអញនឹងមិនសើយចីវរ { ដើទៅ / អង្គុយនៅ } ក្នុងចន្លោះផ្ទះ ។

១១-១២ ។ល។ អាត្មាអញនឹងមិនសើយខ្លាំង { ដើទៅ / អង្គុយនៅ } ក្នុងចន្លោះផ្ទះ ។

---

១-ចំពោះការស្លៀកពាក់ដណ្តប់ក្នុងវត្ត និង ទីក្រៅពីក្នុងភូមិស្រុក ។

២-ចំពោះការស្លៀកដណ្តប់ចូលទៅកាន់ភូមិស្រុក ។

១៣ ១៤ ។ល។ អាត្មាអញនឹងនិយាយសំឡេងតិចៗ ដើរទៅ / អង្គុយនៅ ក្នុងចន្លោះផ្ទះ។

១៥ ១៦ ។ល។ អាត្មាអញនឹងមិនគ្រវែងកាយ ដើរទៅ / អង្គុយនៅ ក្នុងចន្លោះផ្ទះ។

១៧ ១៨ ។ល។ អាត្មាអញនឹង[illegible]របង់បោយ.និងមិនភ្ជាដៃ ដើរទៅ / អង្គុយនៅ ក្នុងចន្លោះផ្ទះ

១៩ ២០ ។ល។ អាត្មាអញនឹងមិនអង្រួនក្បាល ដើរទៅ / អង្គុយនៅ ក្នុងចន្លោះផ្ទះ

២១ ២២ ។ល។ អាត្មាអញនឹងមិនស៊ីមចង្កេះ ដើរទៅ / អង្គុយនៅ ក្នុងចន្លោះផ្ទះ។

២៣ ២៤ ។ល។ អាត្មាអញនឹ[illegible]នទទូរក្បាល ដើរទៅ / អង្គុយនៅ ក្នុងចន្លោះផ្ទះ។

២៥ ។ល។ អាត្មាអញនឹងមិនដើរចំអើតជើង ក្នុងចន្លោះផ្ទះ ។

២៦ ។ល។ អាត្មាអញនឹងមិនអង្គុយគ្របោមក្បាលជង្គង់ ក្នុងចន្លោះផ្ទះ ។

# ភោជនប្បដិសំយុត្តទី ២ មាន ៣០

១-បុព្វជិតគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងទទួលបិណ្ឌបាតដោយ-គោរព ។

២-បុព្វជិតគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញកាលទទួលបិណ្ឌបាត នឹងសំគាល់តែក្នុងបាត្រ ។

៣-។ល។ អាត្មាអញនឹងទទួលបិណ្ឌបាត ឱ្យល្មមគ្នានឹងសម្ល ។

៤-។ល។ អាត្មាអញនឹងទទួលបិណ្ឌបាត ឱ្យស្មើតែត្រឹមកណ្ដាប់មាត់បាត្រ

៥-។ល។ អាត្មាអញនឹងឆាន់បិណ្ឌបាត ដោយគោរព ។

៦-។ល។ អាត្មាអញកាលឆាន់បិណ្ឌបាត នឹងសំគាល់តែក្នុងបាត្រ ។

៧-។ល។ អាត្មាអញនឹងឆាន់បិណ្ឌបាត វាចឱ្យស្មើ ។

៨-។ល។ អាត្មាអញនឹងឆាន់បិណ្ឌបាត ឱ្យល្មមស្មើសំល ។

៩-។ល។ អាត្មាអញនឹងមិនច្រមុចុះត្រង់កំពូលបាយ ហើយឆាន់បិណ្ឌ-បាត្រ ។

១០-។ល។ អាត្មាអញនឹងកកាយបាយលុបសំល ឬម្ហូបគោក[(១)] ព្រោះ

១- សព្ទថា "ម្ហូបគោក" នេះប្រែចេញពីបាលីថា "ព្យញ្ជនៈ" ដែលច្រើនតែធ្លាប់ប្រែរៀងមកថា "ម្ហូបក្រៀម" យើងបានពិនិត្យដោយម៉ត់ចត់ទៅឃើញថា ម្ហូបគោកទោះខាប់ក្ដី ក្រៀមក្ដី ។ ហៅថា "ព្យញ្ជនៈ" ទាំងអស់ទីទៃពីបាលីថា "សូប" ដែលប្រែថា "សំល" ឬថា "សំលទឹក" គឺសំរាប់ហុត ។ ពាក្យថា "ព្យញ្ជនៈ" នេះប្រែថា "ម្ហូប" កុំបាច់ថា "ម្ហូបគោក" ក៏ស៊ឹង តែបាន ដ៏ប្លែកទីទៃពី "សូប" ដែលប្រែថា "សំល" នោះទៅហើយ ។

អាស្រ័យ សេចក្ដីលោភច្រើន ។

១១-។ល។ អាត្មាអញមិនមានជំងឺ នឹងមិនសូមសំល ឬបាយដើម្បីប្រយោជន៍ខ្លួនមកឆាន់ ។

១២-។ល។ អាត្មាអញនឹងមិនសំលឹងរំពៃមើលបាត្រភិក្ខុដទៃ ដោយប្រុងនឹងលើក ទោសគេ ។

១៣-។ល។ អាត្មាអញនឹងមិនធ្វើពំនូតបាយឱ្យធំហួសពេក ។

១៤-។ល។ អាត្មាអញនឹងមិនធ្វើពំនូតបាយឱ្យជាបរិមណ្ឌល គឺឱ្យមូល ។

១៥-។ល។ អាត្មាអញកាលបើពំនូតបាយមិនទាន់ដល់មាត់ នឹងមិនហាមាត់ខាំ ។

១៦-។ល។ អាត្មាអញកាលឆាន់ នឹងមិនញាត់ម្រាមដៃទាំងអស់ឱ្យចូលក្នុងមាត់ ។

១៧-។ល។ អាត្មាអញនឹងមិននិយាយទាំងពំនូតបាយនៅក្នុងមាត់ ។

១៨-។ល។ អាត្មាអញនឹងមិនឆាន់បោះដុំបាយទៅក្នុងមាត់ ។

១៩-។ល។ អាត្មាអញនឹងមិនឆាន់ខាំកាត់ពមនូតបាយមួយកំណាត់ម្ដង ។

២០-។ល។ អាត្មាអញនឹងមិនឆាន់បៀមពំនូតបាយក្នុងថ្ពាល់ ។

២១-។ល។ អាត្មាអញនឹងមិនឆាន់ធ្វើគ្រាប់បាយបាយឱ្យជ្រុះរោយរាយ ។

២៣-។ល។ អាត្មាអញនឹងមិនឆាន់លៀនអណ្ដាត ។ ។

២៤-។ល។ អាត្មាអញនឹងមិនឆាន់ធ្វើសូរឱ្យឮផ្ចប់ៗ ។

២៥-។ល។ អាត្មាអញនឹងមិនឆាន់ធ្វើសូរឱ្យឮគ្រូកៗ ។

២៦-។ល។ អាត្មាអញនឹងមិនឆាន់លិទ្ធដៃ ។

២៧-។ល។ អាត្មាអញនឹងមិនឆាន់លិទ្ធបាត្រ ។

២៨-។ល។ អាត្មាអញនឹងមិនឆាន់លិទ្ធបបូរមាត់ ។

២៩-។ល។ អាត្មាអញនឹងមិនយកដៃដែលប្រឡាក់ដោយអាមិសៈទទួលចាប់កាន់ ភាជនៈទឹក ។

៣០-។ល។ អាត្មាអញនឹងមិនចាក់ទឹកលាងបាត្រទាំងគ្រាប់បាយក្នុងចន្លោះផ្ទះ

## ធម្មទេសនាបដិសំយុត្តទី ៣ មាន ១៦

១-បុព្វជិត គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មាន ជំងឺ មានឆ័ត្រក្នុងដៃ ។

២-បុព្វជិតគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មាន ជំងឺ មានឈើច្រត់ ឬដំបងក្នុងដៃ ។

៣- ។ល។ មានសាស្រ្តាក្នុងដៃ ។

៤- ។ល។ មានអាវុធក្នុងដៃ ។

៥- ។ល។ ពាក់ទ្រនាប់ជើង (១) ។

១-សព្ទថា "ទ្រនាប់ជើង" នេះប្រែចេញពីបាលីថា "បាទុកា" គឺទ្រនាប់ ដែលធ្វើដោយឈើ ឬដោយវត្ថុឯទៀត ក្រៅពីស្បែក. ចំណែកពីបាលីថា "ឧបាហន" ដែលប្រែថា "ស្បែកជើង" ធ្វើដោយស្បែកសត្វមានស្បែកគោជាដើម ។

២-ទោះបីគ្រឿងពាក់សីសៈ មានឬកជាដើម ក៏ទុកដូចជាឈ្នួតក្បាលដែរ

៦- ។ល។ ពាក់ស្បែកជើង ។

៧- ។ល។ នៅលើយាន ។

៨- ។ល។ នៅលើដំណេក ។

៩- ។ល។ អង្គុយគ្របោមក្បាលជង្គង់ ។

១០- ។ល។ ជួតឈ្នួតក្បាល (២) ។

១១- ។ល។ ទទូរក្បាល ។

១២- បុព្វជិតគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញ នឹងមិនអង្គុយផ្ទាល់នឹងផែនដីសំដែងធម៌ដល់មនុស្សគ្មានជំងឺ ដែលអង្គុយលើអាសនៈ

១៣- ។ល។ អាត្មាអញនឹងមិនអង្គុយលើអាសនៈទាប សំដែងធម៌ដល់មនុស្សគ្មានជំងឺ ដែលអង្គុយលើអាសនៈខ្ពស់ ។

១៤- ។ល។ អាត្មាអញនឹងមិនឈរសំដែងធម៌ដល់មនុស្ស គ្មានជំងឺដែលអង្គុយ ។

១៥- ។ល។ អាត្មាអញនឹងមិនដើរខាងក្រោយ សំដែងធម៌ដល់មនុស្សគ្មានជំងឺ ដែលដើរខាងមុខ ។

១៦- ។ល។ អាត្មាអញនឹងមិនដើរក្រៅផ្លូវ សំដែងធម៌ដល់មនុស្សគ្មានជំងឺដែល ដើរក្នុងផ្លូវ ។

# បរិច្ឆេទទី ៤ មាន ៣

១-បព្វជិតគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញគ្មានជំងឺ និងមិនឈរបន្ទោរបង់ ឧច្ចារៈ ឬបស្សាវៈ ។

២-។ល។ អាត្មាអញគ្មានជំងឺ និងមិនបន្ទោរបង់ឧច្ចារៈ ឬបស្សាវៈ ឬក៏ស្តោះ ទឹកមាត់ លើស្មៅស្រស់ ឬឈើស្រស់ ។

៣-។ល។ អាត្មាអញគ្មានជំងឺ និងមិនបន្ទោរបង់ឧច្ចារៈ ឬបស្សាវៈ ឬក៏ស្តោះ ទឹកមាត់ លើទឹក ។

សេក្ខិយវត្ត ទាំង៧៥នេះ បើភិក្ខុណាប្រព្រឹត្តិកន្លងដោយមិនអើពើ ត្រង់សិក្ខាបទណាមួយ ដោយមិនមានហេតុនៃអនាបត្តិទេ ភិក្ខុនោះត្រូវអាបត្តិទុក្កដ (១) ។

---

១- សេក្ខិយវត្តទាំង ៧៥នេះ ជាសាធារណបញ្ញត្តិ. សហធម្មិកបុគ្គលទាំង៥ គឺភិក្ខុ. ភិក្ខុនី. សិក្ខមានា. សាមណេរ. សាមណេរី ត្រូវតែប្រព្រឹត្តិទាំងអស់គ្នា ។ ក្នុងវិមតិវិនោទនីដីកាមហាវគ្គ ត្រង់មហាខន្ធកៈ មានសេចក្ដីបញ្ជាក់ថា សេក្ខិយវត្តក្ខន្ធកវត្តេសុ អញ្ញេសុ ចសក្កតិសេដ្ឋិរចិតលោកវជ្ជសិក្ខាបទេសុ សាមណេរេហិ វត្តិតព្វំគត្ត អវត្តមានោ អលជ្ជី ទណ្ឌកម្មារហោ ច ហោតិ " សាមណេរទាំងឡាយ ត្រូវប្រព្រឹត្តិ (តាមបញ្ញត្តិ) ក្នុងសេក្ខិយវត្ត និង ខន្ធកវត្តទាំងឡាយផង ក្នុងសិក្ខាបទទាំងឡាយឯទៀត ដែលជាលោកវជ្ជៈ ហាក់សក្តិសេដ្ឋិសិក្ខាបទជាដើមផង. (បើសាមណេរណា) មិនប្រព្រឹត្តិ (សាមណេរនោះ)ជាអលជ្ជីផង គួរដល់ទណ្ឌកម្មផង (គឺថាសាមណេរនោះ ឈ្មោះថា ឥតអៀនខ្មាស ខរជ្ជាយ៍ អាចារ្យត្រូវតែធ្វើទណ្ឌកម្មផ្ចាល់ទោសសាមណេរនោះ)" ។

# អធិករណ៍ ៤ យ៉ាង

១-ការវិវាទថា " នេះជាធម៌ ជាវិន័យ " នេះមិនមែនជាធម៌ ជាវិន័យ " ហៅថា វិវាទាធិករណ៍ ។

២-ការចោទគ្នាដោយអាបត្តិនោះៗ ហៅថា អនុវាទាធិករណ៍ ។

៣-អាបត្តិទាំងពួង ហៅថា អាបត្តាធិករណ៍ ។

៤-កិច្ចដែលសង្ឃគប្បីធ្វើ ហៅថា កិច្ចាធិករណ៍ ។

# អធិករណសមថៈ

ធម៌សំរាប់រំងាប់អធិករណ៍ទាំង៤ យ៉ាងនេះ ហៅថា អធិករណ៍សមថៈៗ នេះមាន ៧ យ៉ាង គឺ :

១-ការរំងាប់អធិករណ៍ទាំង៤យ៉ាងនេះ ក្នុងទីចំពោះមុខសង្ឃ ក្នុងទីចំពោះមុខបុគ្គល ក្នុងទីចំពោះមុខវត្ថុ ក្នុងទីចំពោះមុខធម៌ ហៅថា សម្មុខាវិន័យ ។

២-ការដែលសង្ឃសូត្របុ្រកាសឱ្យសម្មតិដល់ព្រះអរហន្តថាលោក ជាអ្នកមាន សតិពេញបរិបូណ៌. ដើម្បីមិនឱ្យអ្នកណាមួយចោទលោកដោយអាបត្តិ ហៅថា សតិវិន័យ ។

៣-ការដែលសង្ឃសូត្រប្រកាសឱ្យសម្មតិដល់ភិក្ខុឆ្កួត ដែលបានជាវិញពីឆ្កួតហើយ ដើម្បីមិនឱ្យមានអ្នកណាចោទអាបត្តិ ដែលលោកធ្វើក្នុងកាល

កំពុង ភ្លូត ហៅថា អមូឡ្ហវិន័យ ។

៤-ការប្រាប់អាបត្តិតាមបេ្តជ្ញារបស់ចំលើយ ដែលឆ្លើយតាមពិហៅថា បដិ-ញ្ញាតករណ ។

៥-ការដាក់ទោសដល់អ្នកដែលខុសហៅថា តស្សបាបិយសិកា ។

៦-ការផ្សះផ្សាអត់ឱនគ្នា ទាំងពីរចំណែក មិនបាច់ជំនុំជំរះ សេចក្ដីដើម ហៅថា តិណវត្ថារក ។

សិក្ខាបទក្រៅពីនេះ ដែលលើកឈ្មោះឡើងជាអាបត្តិថុល្លច្ច័យខ្លះ ទុក្កដខ្លះ ទុព្ភាសិតខ្លះ ជាសិកាបទ ដែលមិនមានក្នុងបាតិមោក្ខ ។ បព្វជិត ជាសិក្ខាកាម ត្រូវសិក្សាតាមលំដាប់របស់ខ្លួន ឱ្យចេះចាំនូវសិក្ខាបទទាំងនោះតទៅទៀតចុះ ។

## - ឥន្ទ្រិយសំវរសីល

សីលគឺការសង្រួមឥន្ទ្រិយ ៦ យ៉ាង គឺ

១-ចក្ខុន្ទ្រិយសំវរ សង្រួមចក្ខុន្ទ្រិយ

២-សោតិន្ទ្រិយសំវរ សង្រួមសោតិន្ទ្រិយ

៣-ឃានិន្ទ្រិយសំវរ សង្រួមឃានិន្ទ្រិយ

៤-ជិវ្ហិន្ទ្រិយសំវរ សង្រួមជិវ្ហិន្ទ្រិយ

៥-កាយិន្ទ្រិយសំវរ សង្រួមកាយិន្ទ្រិយ

៦-មនិន្ទ្រិយសំវរ សង្រួមមនិន្ទ្រិយ (*ចប់ឥន្ទ្រិយសំវរសីលទី២*)

## អាជីវបារិសុទ្ធិសីល

សីលដែលបរិសុទ្ធដោយការចិញ្ចឹមជីវិត

វៀរចាកបាបធម៌ ៥ និង អនេកសនៈ ២១

## បាបធម៌ ៥ នោះគឺ

១-កុហនា ការកុហកដោយឫកពារ

២-លបនា ការនិយាយរាក់ទាក់ដោយវាចា

៣-នេមិត្តិកតា ការធ្វើនូវនិមិត្ត គឺប្រើឧបាយកលដោយកាយ

ខ្លះ ដោយវាចាខ្លះ ។

៤-និប្បេសិកតា ការពោលគំរាម ឬសង្កត់ប្រើសំដីជាខ្លាំង
សំរាប់កោសការ យកលាភ ។

៥-លាភេន លាភំ និជិគីសនតា ការរកលាភដោយលាភ
គឺការយកលាភទៅទាក់លាភ ។

## អនេសនៈ២១នោះ [១] គឺ

១-វេឡុទានំ ការឱ្យឫស្សី

២-បត្តទានំ ការឱ្យស្លឹកឈើ

៣-បុប្ផទានំ ការឱ្យផ្កាឈើ

៤-ផលទានំ ការឱ្យផ្លែឈើ

៥-ទន្តកដ្ឋទានំ ការឱ្យឈើស្ទន់

៦-មុខោទកទានំ ការឱ្យទឹកលុបមុខ

៧-សិនានទានំ ការឱ្យវត្ថុសំរាប់ងូត សំរាប់គក់

៨-ចុណ្ណទានំ ការឱ្យគ្រឿងលំអិតសំរាប់លាប

៩-មត្តិកាទានំ ការឱ្យដីស្អិត

១០-ចាដុកម្យតា ការប្រព្រឹត្តិបន្ទាបបន្ទន់កាយវាចា

១១-មុគ្គសូបតា ការពោលពាក្យពិតខ្លះ មិនពិតខ្លះដូចជាសំល

១-[illegible]

សណ្ដែកបាយ

១២-បារិភដ្យតា ការផ្គាប់ផ្គុនគ្រហស្ថ

១៣-ជង្ឃបេសនិកំ ការបំរើគ្រហស្ថដោយកំលាំងស្មង

១៤-វេជ្ជកម្មំ ការធ្វើពេទ្យរក្សាជំងឺ

១៥-ទូតកម្មំ ការធ្វើជាទូត (នាំដំណឹងរបស់គ្រហស្ថ) ។

១៦-បហិណគមនំ ការទទួលខ្លួនជាអ្នកបំរើគ្រហស្ថឱ្យគេប្រើទៅមក (ក្រៅអំពីការនាំដំណឹង) ។

១៧-បិណ្ឌប្បដិបិណ្ឌិកំ ការឱ្យចង្ហាន់បិណ្ឌបាត្រដល់គ្រហស្ថ ហើយស្វែងរក ហើយបរិភោគខ្លួនឯង ជាខាងក្រោយ ។

១៨-ទានូបទានំ ការឱ្យទៅឱ្យមក

១៩-វត្ថុវិជ្ជា ការរៀនវិជ្ជាធ្វើជាគ្រូ មើលទីដីជាយភូមិ ។

២០-នក្ខត្តវិជ្ជា ការរៀនវិជ្ជា ធ្វើជាគ្រូមើលនក្ខត្ត ឬក្សមានចាប់យាម មើលថ្ងៃ ខែជាដើម ។

២១-អង្គវិជ្ជ ការរៀនវិជ្ជាធ្វើគ្រូទាយលក្ខណៈខ្លួនប្រាណ ។

*(ចប់អាជីវបារិសុទ្ធសីលមាតិកា)*

# បច្ចយសន្និស្សិតសីល

សីលដែលអាស្រ័យនូវបច្ច័យ.បច្ច័យនោះមាន៤យ៉ាងគឺ

១-ចីវរប្បច្ចយ បច្ច័យ គឺគ្រឿងសំរាប់ស្លៀក ដណ្ដប់ ។

២-បិណ្ឌបាតប្បច្ចយ បច្ច័យ គឺគ្រឿងសំរាប់បរិភោគ ។

៣-សេនាសនប្បច្ចយ បច្ច័យគឺគ្រឿងសំរាប់ដេកនិងទីសំរាប់អង្គុយ

៤-គិលានភេសជ្ជប្បច្ចយ បច្ច័យ គឺថ្នាំសំរាប់ព្យាបាលជំងឺ ។

# បច្ចវេក្ខណាវិធី

វិធីសំរាប់ពិចារណា ក្នុងបច្ច័យមួយៗនោះ មាន ៤ ៗ គឺ

១-ធាតុប្បច្ចវេក្ខណា ពិចារណានូវបច្ច័យថាគ្រាន់តែជាធាតុ ។

២-បដិកូលប្បច្ចវេក្ខណា ពិចារណានូវបច្ច័យថាជារបស់បដិកូល ។

៣-តំខណិកប្បច្ចវេក្ខណា ពិចារណានូវបច្ច័យ ក្នុងខណៈនោះគឺក្នុងពេលកំពុងបរិភោគ ។

៤-អតីតប្បច្ចវេក្ខណា ពិចារណានូវបច្ច័យ ដែលបានបរិភោគកន្លងទៅហើយបច្ច័យមួយៗ មានបច្ចវេក្ខណៈបួនៗ ដូចខាងលើនេះ រួមត្រូវជាបច្ចវេក្ខណៈ១៦ ។

## បច្ចវេក្ខណកាល

កាលដែលត្រូវពិចារណា ក្នុងបច្ច័យមួយៗនោះ មាន បី ៗ គឺ

១-បដិលាភកាល កាលដែលកំពុងបាន ឬកំពុងទទួលនូវបច្ច័យ ។

២-បរិភោគកាល កាលដែលកំពុងបរិភោគប្រើប្រាស់នូវបច្ច័យ ។

៣-អតីតកាល កាលដែលបានបរិភោគប្រើប្រាស់នូវបច្ច័យ កន្លងទៅហើយ ។

បច្ច័យមួយៗ មានកាលបីៗ រួមត្រូវជាកាល១២ ។

## ចីវរប្បច្ចយ

កំណត់ដែនរបស់ប្រយោជន៏ ៤ យ៉ាង គឺ

១-សីតស្ស បដិឃាតាយ ដើម្បីការពារ នូវត្រជាក់ ។

២-ឧណ្ហស្ស បដិឃាតាយ ដើម្បីការពារ នូវកំដៅ ។

៣-ឌំស មកស វាតាតប សិរីសប សម្ផស្សានំ បដិឃាតាយ ដើម្បី ការពារនូវសម្ផស្សនៃរបោម, មូស, ខ្យល់, កំដៅថ្ងៃ, ពស់តូច និង ពស់ធំទាំងឡាយ ។

៤-ហិរិកោបិនប្បដិច្ឆាទនត្ថំ បដិឃាតាយ ដើម្បីបិទបាំងនូវអវយវៈដែលធ្វើនូវសេចក្ដីខ្មាសឱ្យកំរើក ។

# បិណ្ឌបាតប្បច្ចយ

ចាត់ជាអង្គត្រូវឃាត់ ៤. ដែលជាដែនរបស់ប្រយោជន៍ ៨. រួមទាំងអស់ត្រូវជាអង្គ ១២ គឺ :

១-នេវ ទវាយ មិនមែនដើម្បីល្បែងលេង ដូចក្មេងអ្នកស្រុក ។

២-ន មទាយ មិនមែនដើម្បីឱ្យកើតបុរិសមានៈស្រវឹងដូចអ្នកប្រដាល់

៣-ន មណ្ឌនាយ មិនមែនដើម្បីប្រដាប់តាក់តែងរាងកាយដូច ស្រ្តីក្នុងបុរី គឺ ស្រ្តីអ្នកក្រុង ។

៤-ន វិភូសនាយ មិនមែនដើម្បីស្អិតស្អាងរាងកាយឱ្យមានសម្បុរផូរផង់ដូចអ្នកលេងរបាំ ។

(ទាំងនេះជាអង្គត្រូវឃាត់ មិនមែនជាដែនរបស់ប្រយោជន៍ទេ) ។

៥-ឥមស្ស កាយស្ស ឋិតិយា ដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ។

៦-យាបនាយ ដើម្បីញុំាងជីវិតតិន្ទ្រីយឱ្យប្រព្រឹត្តទៅ ។

៧-វិហិំសុបរតិយា ដើម្បីបំបាត់នូវសេចក្តីលំបាក ។

៨-ព្រហ្មចរិយានុគ្គហាយ ដើម្បីអនុគ្រោះដល់ព្រហ្មចរិយធម៌

៩-ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ ដូច្នេះអាត្មាអញនឹងកំចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លាន ដែលមានហើយផង ។

១០-នវញ្ច វេទនំ ន ឧប្បាទេស្សាមិ អាត្មាអញនឹងមិនញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណឱ្យកើតឡើងបានផង ។

១២-អនវជ្ជតា ច សេចក្ដីមិនមានទោស ហានមិនប្រទូសកាយ មិនប្រទូសចិត្តជាដើម (.ងមានដល់អាត្មាអញផង) ។

អង្គទាំង៨នេះជាដែនរបស់ប្រយោជន៍ ។ នៅមានសល់អង្គមួយទៀត គឺ ផាសុវិហារតា ច " ការនៅសប្បាយក្នុងឥរិយាបថទាំង៤ (និងមានដល់អាត្មាអញផង) ។ ប៉ុន្តែអង្គមួយនេះ លោកមិនរាប់បញ្ចូលរួមជាមួយនឹងអង្គ១២ ខាង លើទេ ព្រោះចាត់ជាអានិសង្សរបស់ភោជន ។

## សេនាសនប្បច្ចយ

មានកំណត់ដែនរបស់ប្រយោជន៍ ៥ យ៉ាង គឺ

១-សីតស្ស បដិឃាតាយ ដើម្បីការពារនូវត្រជាក់

២-ឧណ្ហស្ស បដិឃាតាយ ដើម្បីការពារ នូវកំដៅ ។

៣-ឌំស មកសវាតាតប សិរីសប សម្ផស្សានំ បដិឃាតាយ ដើម្បីការពារ នូវសម្ផស្សនៃរបោម, មូស, ខ្យល់, កំដៅថ្ងៃ, ពស់តូច និង ពស់ធំទាំងឡាយ ។

៤-ឧតុ បរិស្សយវិនោទនំ ដើម្បីបន្ទោរបង់នូវក្រវល់ក្រវាយដែលកើតអំពីរដូវ ។

៥-បដិសល្លានារាមត្ថំ ដើម្បីប្រមូលចិត្តអំពីអារម្មណ៍ផ្សេងៗ ហើយអភិរម្យ សំងំនៅក្នុងកម្មដ្ឋាន ។

## គិលានភេសជ្ជប្បច្ចយ

មានកំណត់ដែនរបស់ប្រយោជន៍ត្រឹមតែ ១ យ៉ាង គឺ

ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយ ដើម្បីការពារនូវទុក្ខវេទនាទាំងឡាយ ដែលកើតឡើងហើយ ដរាបទៅដល់ត្រឹម ប្រាសចាកសេចក្តីទុក្ខ។

## បរិភោគ

ការបរិភោគប្រើប្រាស់ នូវបច្ច័យ ចែកចេញតាមប្រភេទរបស់បុគ្គលអ្នកប្រើប្រាស់ មាន ៤យ៉ាងគឺ :

១-ថេយ្យបរិភោគ  បរិភោគដោយការលួច បានដល់ការបរិភោគ របស់ភិក្ខុ ទ្រុស្តសីល ។

២-ឥណបរិភោគ  បរិភោគដោយបំណុល បានដល់ការបរិភោគរបស់ភិក្ខុមានសីល តែដែលពុំបានពិចារណា ។

៣-ទាយជ្ជបរិភោគ  បរិភោគនូវមតិដែលត្រូវបាន, បានដល់ការបរិភោគរបស់បព្វជិត ជាសេក្ខបុគ្គល៧ពួក[១], និងបព្វជិតជាកល្យាណបុថុជ្ជន ។

៤-សាមិបរិភោគ បរិភោគរបស់ជនមានម្ចាស់, បានដល់ការបរិភោគរបស់បព្វជិតជាអសេក្ខបុគ្គល[២] គឺ ខីណាសវបព្វជិត ។

- ចប់ បច្ច័យសន្និស្សិត សីលទី៤ -

---

១-បុគ្គលដែលបានសំរេច សោតាបត្តិមគ្គ១. សោតាបត្តិផល១. សកទាគាមិមគ្គ១. សកទាគាមិផល១. អនាគាមិមគ្គ១.អនាគាមិផល១. អរហត្តមគ្គ១ ទាំង ៧ នេះហៅថា សេក្ខបុគ្គល ព្រោះនៅមានការសិក្សា ដើម្បីឱ្យបាន សំរេចអរហត្តផលតទៅទៀត ។

២-បុគ្គលដែលបានសំរេចអរហត្តផលហើយ ហៅថា អសេក្ខបុគ្គល ព្រោះអស់ការសិក្សា ដើម្បីបាន ផលទៅទៀតហើយ ។

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណ: ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **សំ ហ្សឺនី**

កញ្ញា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដាវី ព្រមទាំងលោកស្រី បុប្ផា ដឺឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៉ឺស និងលោកម្ដាយ ឌិន សៅខុន

សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org